បានដោយមិនធ្វើបត្យាប័ណ្ណ ។ ប្រមុខរដ្ឋាភិបាលកម្ពុជាបានលើកហេតុផលថា លោក **ថាក់ស៊ីន** ជាមិត្តល្អរបស់គាត់ " **ជួយមិត្តក្នុងគ្រាលំបាក** " បើរឿងនេះពិតមែន អាចបង្ហាញថា **គេយករឿងបុគ្គលមិត្តភ័ក្ត្រផ្ទាល់ខ្លួន មកលាយឡំរឿងប្រទេសជាតិ**។ ហើយលោក **ថាក់ស៊ីន** ពេលនេះជាអ្នកនយោបាយកំពុងតែដើរតួសំខាន់នៅក្នុងទំនាស់នយោបាយប្រទេសថៃទៀតផង ។

**គណបក្សសិទ្ធិមនុស្ស** យល់ឃើញថា បើគ្រប់ភាគី ទាំងអ្នកដឹកនាំរដ្ឋាភិបាលថៃ ទាំងគូរប្រកួតថៃ គឺលោក **ថាក់ស៊ីន** និងទាំងប្រមុខរដ្ឋាភិបាលកម្ពុជា មិនគិតតែពីប្រយោជន៍ ឬប្រជាប្រិយភាពផ្ទាល់ខ្លួន ឬបក្សខ្លួន ហើយមិនចង់ឱ្យមានទំនាស់មិនចង់ឱ្យមានសង្គ្រាម មិនចង់ឱ្យប្រជាពលរដ្ឋខ្លួនរងទុក្ខវេទនានោះទេ គួរតែនាំគ្នាជួបចរចារគ្នាបន្ធូរបន្ថយភាពតានតឹងនេះបាន ដោយផ្តើមពីការដោះស្រាយទំនាស់ពីឬសគល់ដើម គឺកងទ័ពថៃឈប់មកបង្កទំនាស់លើទឹកដីខ្មែរ ជាពិសេសតំបន់ប្រាសាទព្រះវិហារឱ្យជ្រះស្រឡះ ទទួលស្គាល់ច្បាប់អន្តរជាតិថា ប្រាសាទព្រះវិហារជាប្រាសាទរបស់ខ្មែរ។ ហើយភាគីកម្ពុជា ជាពិសេសប្រមុខរដ្ឋាភិបាលកម្ពុជា កុំយកបញ្ហាមិត្តភ័ក្ត្រផ្ទាល់ខ្លួន ឬបញ្ហាគណបក្សខ្លួនមកលាយឡំបញ្ហាជាតិ ព្រោះរដ្ឋាភិបាលគឺជារបស់ជាតិ របស់ប្រជាពលរដ្ឋខ្មែរគ្រប់គ្នា មិនមែនជាកម្មសិទ្ធផ្ទាល់ខ្លួននោះទេ។ ពោលគឺបើចង់បានលោក **ថាក់ស៊ីន** ធ្វើទីប្រឹក្សាសេដ្ឋកិច្ចគួររង់ចាំ លោក **ថាក់ស៊ីន** ដោះស្រាយបញ្ហានយោបាយជាមួយរដ្ឋាភិបាលថៃបច្ចុប្បន្ន ដែលរដ្ឋាភិបាលកម្ពុជាទទួលស្គាល់សហការណ៍កន្លងមកនោះឱ្យចប់សិន។

**សរុបមកគណបក្សសិទ្ធិមនុស្ស យល់ឃើញថា :**

១. រដ្ឋាភិបាលថៃត្រូវតែទទួលស្គាល់ថា ប្រាសាទព្រះវិហារជារបស់ប្រទេសកម្ពុជា ស្របតាមច្បាប់អន្តរជាតិ ហើយកងទ័ពថៃត្រូវបញ្ឈប់ការបង្ករឿងនៅលើទឹកដីខ្មែរតាមតំបន់ព្រំដែនជាបន្ទាន់។

២. រដ្ឋាភិបាលកម្ពុជា គួរតែទុកឱ្យបញ្ហាផ្ទៃក្នុងរវាងរដ្ឋាភិបាលថៃ និង លោក **ថាក់ស៊ីន** ដោះស្រាយដោយភាគីទំនាស់ផ្ទៃក្នុងរបស់គេដើម្បីកុំឱ្យប៉ះពាល់ និងខាតផលប្រយោជន៍ខ្មែរយើង។

៣. ទោះជាយ៉ាងណាក៏ដោយ ក្នុងស្ថានភាពប្រឈមមុខជាមួយបរទេសនេះ ប្រជាពលរដ្ឋខ្មែរគ្រប់និន្នាការ គ្រប់គណបក្សនយោបាយទាំងអស់ ត្រូវមានចំណែកក្នុងការចូលរួមការពារផលប្រយោជន៍ជាតិ និងផលប្រយោជន៍ប្រជាពលរដ្ឋខ្មែរ ដោយរួមសាមគ្គីគ្នាតម្កល់បញ្ហាជាតិធំជាងបញ្ហាផ្ទាល់ខ្លួន និងបញ្ហាគណបក្សនយោបាយរបស់ខ្លួន។

ពត៌មានបន្ថែមទាក់ទង : ០១១ ៧៧៧ ៧៥០